**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀង**
**រវាង**
**រោងចក្រ ព្រីនធីង ដេល (ខេមបូឌា) ខូអិលធីឌី**
**និង**
**តំណាងប្រតិភូបុគ្គលិក នៃរោងចក្រ ព្រីនធីង ដេល (ខេមបូឌា) ខូអិលធីឌី**
**ស្តីពី ការព្យួរកិច្ចសន្យាការងារ**

នាព្រឹកថ្ងៃទី23 ខែមេសា ឆ្នាំ២០២០ វេលាម៉ោង 8:00នាទី មានកិច្ចប្រជុំរវាងតំណាងរោងចក្រ ព្រីនធីង ដេល (ខេមបូឌា) ខូអិលធីឌី លោកស្រី នួន សូហ្វីយ៉ា និងតំណាងប្រតិភូបុគ្គលិកទាំងអស់ ស្តីពីការព្យួរកិច្ចសន្យាការងារ នៅបន្ទប់ប្រជុំប្រតិភូ។

ជាកិច្ចចាប់ផ្តើមលោកស្រី នួន សូហ្វីយ៉ា បានសម្តែងនូវការស្វាគមន៍ចំពោះបងប្អូនជាតំណាងប្រតិភូបុគ្គលិកទាំងអស់ដែលចូលរួមកិច្ចប្រជុំនេះ បន្ទាប់មកលោកស្រីក៏បានថ្លែងអំពីស្ថានភាពទូទៅ នៃការឆ្លងរីករាលដាលជំងឺកូវីដ-19 ជុំវិញពិភពលោក ក្នុងនោះក៏មានកម្ពុជាផងដែរ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរលើវិស័យវាយនភណ្ឌ កាត់ដេរជាដើម ។ល។

យោងតាមសេចក្តីណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈលេខ០៤៥/២០ ក.ប/ស.ណ.ន.ខ.ល ស្តីពីការព្យួរកិច្ចសន្យាការងារ និងផ្តាកបង់ភាគទាន ប.ស.ស. សម្រាប់រោងចក្រ សហគ្រាស គ្រឹះស្ថានក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីដ-១៩ រោងចក្រសម្រេចស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១២៤នាក់ ស្រី ៥៧នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១២៩នាក់ រយៈពេល ២ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែឧសភា រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ដោយមូលហេតុ ខ្វះការបញ្ជាទិញ និងខ្វះសម្ភារវត្ថុធាតុដើមមួយចំនួនសម្រាប់ផលិតផលិតផល។

ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ តំណាងរោងចក្រ និងតំណាងប្រតិភូបុគ្គលិកទាំងអស់បានព្រមព្រៀងដូចតទៅៈ

- ប្រាក់ឧបត្ថម្ភពីនិយោជកជូនកម្មករនិយោជិតចំនួន ៣០ដុល្លារអាមេរិក ក្នុង១ខែ ដោយធ្វើការទូទាត់នៅរៀងរាល់បំណាច់ខែ នៃខែនីមួយៗ តាមរយៈលេខគណនី នៅធនាគារ ABA របស់បងប្អូនកម្មករនិយោជិត។
- ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលចំនួន ៤០ដុល្លារអាមេរិក ក្នុង១ខែ។

ក្នុងករណីរោងចក្រទទួលបានការបញ្ជាទិញ និងសម្ភារវត្ថុធាតុដើមគ្រប់ចំនួនមុនកាលកំណត់នៃរយៈពេលព្យួរកិច្ចសន្យាការងារ នោះរោងចក្រនឹងទូរសព្ទហៅបងប្អូនកម្មករនិយោជិតអោយចូលបម្រើការងារជាធម្មតា និងរក្សាជូននូវអត្ថប្រយោជន៍ផ្សេងៗនៅដដែល។ ដោយឡែកសម្រាប់បងប្អូនកម្មករនិយោជិត ដែលខកខានមិនបានចូលធ្វើការតាមពេលវេលាកំណត់ក្រោយបញ្ចប់រយៈពេលព្យួរកិច្ចសន្យាការងារនោះ រោងចក្រនឹងអនុវត្តតាមច្បាប់ស្តីពីការងារ និងបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ៩:០០នាទី ថ្ងៃខែឆ្នាំដដែល។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០
ហត្ថលេខា និងត្រា
ជ. ម្ចាស់ ឬនាយក

PRINTING JEIL (CAMBODIA) Co., Ltd.

-កិច្ចព្រមព្រៀងនេះធ្វើឡើងចំនួន 3ច្បាប់
-1ច្បាប់តម្កល់នៅរោងចក្រ
-1ច្បាប់សម្រាប់ភ្ជាប់ជាមួយលិខិតស្នើសុំព្យួរកិច្ចសន្យាការងារ
-1ច្បាប់សម្រាប់ជូនតំណាងប្រតិភូបុគ្គលិក

ប្រតិភូបុគ្គលិកពេញសិទ្ធិ



ម៉ម កុសល

ប្រតិភូជំនួយ



ទិត សម្ផស្ស



ទុយ ណារ៉ា



ណុះ សារ៉ាន់



ហៃ ឡៃ